# ការថ្វាយព្រះពរ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ចំពោះព្រះករុណាព្រះបរមនាថសីហមុនី
## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
## សុំព្រះរាជទានធ្វើអន្តរាគមន៍លើកលែងទោស
## និងលើកការចោទប្រកាន់ចំពោះបក្សប្រឆាំង
## និងសកម្មជនសិទ្ធិមនុស្ស

web site: hoksavann.org

តុលាការនៅក្រោមឥទ្ធិពលរាជរដ្ឋាភិបាល បានកាត់ទោសសមាជិកសភានៃគណបក្សប្រឆាំងពីរនាក់គឺ ម្នាក់ឲ្យជាប់ពន្ធនាគារ៧ឆ្នាំ និងម្នាក់ទៀតឲ្យជាប់ពន្ធនាគារ ១៨ខែ ពីបទបង្កូទ័ពខុសច្បាប់ និងបទបរិហារកេរ្តិ៍ ។ មួយទៀត បានចោទសកម្មជនសិទ្ធិមនុស្សនិងអ្នកសារពត៌មានជាច្រើននាក់ ដែល៥នាក់ទើបតែដោះលែងឲ្យនៅក្រៅឃុំ ហើយជាច្រើននាក់ទៀតរត់ភៀសខ្លួនទៅក្រៅប្រទេស ដែលក្នុងនោះមានព្រះរាជវង្សម្នាក់ផង ដោយចោទពីបទបរិហាកេរ្តិ៍តាមច្បាប់ព្រហ្មទណ្ឌអន្តរកាលសម័យអ៊ុនតាក់ ។ មតិជាតិ-អន្តរជាតិបានចោទរាជរដ្ឋាភិបាលខ្មែរ ថាបានប្រើតុលាការដែលស្ថិតនៅក្រោមឥទ្ធិពលខ្លួន ឲ្យកំចាត់គណបក្សប្រឆាំង និងបំបិទមាត់សកម្មជនការពារសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ដែលរិះគន់ខ្លួន ។

ដោយមានភាពមិនឯករាជ្យនៃប្រព័ន្ធតុលាការខ្មែរ ដែលមានលក្ខណៈនយោបាយក្នុងការកាត់ទោសនិងការចោទប្រកាន់នេះហើយ បានជាប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ត្រូវការព្រះមហាក្សត្ររបស់ខ្លួន ដែលជាស្ថាប័នកំពូល បំពេញនាទីរបស់ព្រះអង្គក្នុងព្រះរាជសិទ្ធិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នត្រង់មាត្រា៧ចែងថា អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ ។ មាត្រា៨ចែងថា ព្រះមហាក្សត្រទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ ។ មាត្រា២៧ចែងថា ព្រះមហាក្សត្រទ្រង់មានរាជសិទ្ធិបន្ធូរបន្ថយទោសនិងលើកលែងទោស ។ ព្រះរាជសិទ្ធិនេះ ជាអំណាចគ្រប់គ្រាន់ ក្នុងការធ្វើអន្តរាគមន៍

ទៅរាជរដ្ឋាភិបាលខ្មែរ ៖

១- សូមឲ្យលើកលែងទោសមាជិកសភានៃគណបក្សប្រឆាំងពីរនាក់ ដែលតុលាការកាត់មានទោស ។

២- សូមលើកលែងការចោទប្រកាន់ សកម្មជនសិទ្ធិមនុស្សនិងអ្នកសារពត៌មានទាំងអស់ អំពីបទបរិហារកេរ្តិ៍ ។

៣- ទុកច្បាប់អ៊ុនតាក់ អំពីបទបរិហារកេរ្តិ៍ជាទោសព្រហ្មទណ្ឌជានិរាករណ៍ ។

៤- មិនបង្កើតច្បាប់ថ្មី អំពីបទបរិហារកេរ្តិ៍ជាទោសព្រហ្មទណ្ឌ ។

៥- ជំរុញឲ្យមានការប្រជុំឡើងវិញ នូវសន្និសិទអន្តរជាតិទីក្រុងប៉ារីសប្រទេសបារាំងឆ្នាំ១៩៩១ ស្តីអំពីកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជា ដែលមានសមាជិក១៩ប្រទេស ដើម្បីពិនិត្យឡើងវិញនូវការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាព ចាប់ពីពេលនោះរហូតមកដល់ពេលនេះ តើបានត្រឹមត្រូវទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះឬទេ ? មានបញ្ហាឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី ដែលមានបញ្ហាចំរូងចំរាស់រហូតចាប់ដាក់គុក គ្រាន់តែបញ្ចេញយោបល់អំពីបញ្ហាទឹកដីនេះជាដើម ។

កាលបើព្រះរាជសិទ្ធិនេះបានត្រូវអនុវត្ត នោះស្ថាប័នព្រះមហាក្សត្រពិតជាមានតម្លៃខ្ពង់ខ្ពស់សំរាប់ប្រជាជាតិខ្មែរ ជាពិសេសសំរាប់ប្រជាពលរដ្ឋ ដែលទទួលរងទុក្ខដោយអំពើអយុត្តិធម៌ ដោយប្រជាពលរដ្ឋចាត់ទុកថា ព្រះមហាក្សត្របានរួមសុខរួមទុក្ខជាមួយខ្លួន ដូចព្រះរាជឱង្ការរបស់ព្រះបាទជ័យវរ្ម័នទី៧ថា សេចក្តីទុក្ខរបស់ប្រជារាស្ត្រ គឺជាសេចក្តីទុក្ខរបស់ព្រះអង្គ ។ អនាគមន៍របស់ព្រះមហាក្សត្រពេលនេះ ទុកជាអ្នកអាជ្ញាកណ្តាល រកយុត្តិធម៌ជូនប្រជាពលរដ្ឋ ដែលជាមាគ៌ាដ៏ត្រឹមត្រូវរបស់ព្រះពុទ្ធសាសនា ។ ទុកជាការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ឲ្យមានស្ថេរភាពខាងផ្លូវនយោបាយ ជំរុញឲ្យមានសីលធម៌ ដែលជាតម្លៃរបស់មនុស្សជាតិ ។ ទុកជាការលើកដំកើងនិងជម្រុញសកម្មជនសិទ្ធិមនុស្សនិងអ្នកប្រជាធិបតេយ្យ ឲ្យដើរទៅមុខ ។

វត្តខ្មែរកាណាដា, ថ្ងៃទី២០ មករា ២០០៦
ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

❑ ❑

❑